**សេចក្តីថ្លែងការណ៍រួមរបស់អង្គការពលកម្មអន្តរជាតិ (ILO) និង ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ស្វាគមន៍សេចក្តីសម្រេចរបស់តុលាការកំពូលនៅ ក្នុងករណីឃាតកម្មលើមេដឹកនាំសហជីពកម្មករ លោក ជា វិជ្ជា**

២៥ កញ្ញា ២០១៣ ទីក្រុងបាងកក និងរាជធានីភ្នំពេញ - ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) និងការិយាល័យពលកម្មអន្តរជាតិ(ILO) សូមស្វាគមន៍ចំពោះសេចក្តីសម្រេចចិត្តរបស់តុលាការកំពូលកម្ពុជា ដែលបានសម្រេចឲ្យរួចខ្លួន ដល់លោក ប៊ន សំណាង និងលោក សុខ សំអឿន ដែលកន្លងមកត្រូវបានតុលាការផ្តន្ទាទោសពីបទឃាតកម្មលើមេដឹកនាំសហជីពកម្មករ លោក **ជា វិជ្ជា** ។

បន្ទាប់ពីបានដំណើរការនីតិវិធីអស់ពេលជាងប្រាំបួនឆ្នាំនៅចំពោះមុខតុលាការកម្ពុជាមក លោក ប៊ន សំណាង និង លោក សុខ សំអឿន នៅទីបំផុតត្រូវបានជម្រះចេញនូវរាល់ពិរុទ្ធភាពទាំងអស់នៅក្នុងករណីនេះ។ តុលាការកំពូលបានទទួលស្គាល់អំពីការខ្វះភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីពិរុទ្ធភាពរបស់បុរសទាំងពីរនាក់នេះ ហើយក៏បានកំណត់អំពីចំណុចខ្វះខាតមួយចំនួន ដែលនគរបាលបានចាត់ការលើករណីនេះ។ ជាពិសេស តុលាការកំពូលបានសង្កត់ធ្ងន់ថា ចម្លើយសារភាពដោយបង្ខំពីលោក ប៊ន សំណាង ដោយនគរបាល មិនអាចប្រើប្រាស់ធ្វើជាភស្តុតាងនៅក្នុងតុលាការបានឡើយ។

ខណៈពេលដែលការិយាល័យប្រចាំប្រទេសនៃអង្គការពលកម្មអន្តរជាតិ(ILO)ប្រចាំប្រទេសថៃឡង់ដ៏ កម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) សូមស្វាគមន៍ចំពោះការសម្រេចឲ្យរួចខ្លួន និងការដោះលែងបុរសទាំងពីរនាក់នេះនៅពេលដ៏ឆាប់ខាងមុខ អង្គការនេះបានរំលឹកឡើងវិញអំពីការសង្កត់ធ្ងន់ពីស្ថាប័នគ្រប់គ្រងអន្តរជាតិនានា លើតម្រូវការឲ្យមានការស៊ើបអង្កេតពេញលេញមួយក្នុងករណីឃាតកម្មលើលោក ជា វិជ្ជា ដើម្បីធ្វើឲ្យប្រាកដថាជនល្មើសពិតប្រាកដ ត្រូវបានចោទប្រកាន់ ជំនុំជម្រះ និងផ្តន្ទាទោសទៅតាមច្បាប់។

ចប់.